# បញ្ជីឆែកមើលនៃគ្រឿងឲ្យសញ្ញាពេលមានផ្សែងដែលសំរាប់ប្រើនៅតាមផ្ទះ

Fact Sheet 11 – Community Risk Management. Revised 28/09/2004 - Language

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## ហេតុការណ៍

ផ្សែងចេញពីភ្លើងឆេះផ្ទះជាផ្សែងពុល, មានតែការប្រមានមុនប៉ុណ្ណោះដែលអាចជួយផ្តល់ពេលដ៏សំខាន់ដល់គ្រួសារលោកអ្នកឲ្យគេចចេញពីបន្ទប់មួយដែលពោរពេញទៅដោយផ្សែង ។ មិនតែប៉ុណ្ណោះពេលលោកអ្នកទទួលទានដំណេកលក់ លោកអ្នកពុំធុំក្លិនផ្សែងពីភ្លើងឆេះទេ ហើយតាមការពិតផ្សែងនោះនឹងធ្វើឲ្យលោកអ្នកកាន់តែលក់ថែមទៀតផង ។ គ្រឿងឲ្យសញ្ញាពេលមានផ្សែង (smoke alarms)មួយអាចផ្តល់ការព្រមានមុនដែលលោកអ្នកត្រូវការហើយជាជំហានសំខាន់ទីមួយនៅក្នុងផែនការសុវត្ថិភាពនៃភ្លើងឆេះផ្ទះរបស់លោកអ្នក ។.

## តើ smoke alarms មានប៉ុន្មានប្រភេទដែលគេរកបានសំរាប់ដាក់នៅតាមផ្ទះ?

(smoke alarms) ដែលគេអាចរកបានគឺ Hard wired smoke alarms (តភ្ជាប់នឹងខ្សែអគ្គិសនីហើយមានថ្មជាជំនួយ) ឬBattery powered smoke alarms ប្រើដោយថ្ម ។ មានច្រើនប្រភេទទៀតដែលសំរាប់ប្រើនៅក្នុងផ្ទះបាយហើយនិងការ៉ាវ៉ានហើយនិងសំរាប់អ្នកត្រូវការពិសេសដូចជាអ្នកមានត្រចៀកខ្សោយជាដើម ។ មានប្រភេទច្រើនទៀតដែលមានសម្លេងបញ្ចូលជាមួយភ្លើងអាសន្នផងដែរ (incorporating an emergency light)។

### ទោះជាប្រភេទណាមួយក៏ដោយដែលលោកអ្នកសម្រេចយកមកប្រើ យើងសូមផ្តល់ឱវាទថា ៖

- ☐ ផ្ទះ ឬផ្ទះយូនិត (unit) មានដាក់(smoke alarms) ដែលអាចប្រើបានមួយចំនួនដែលសមទៅតាមទំហំផ្ទះ ឬយូនិតនោះ ។
- ☐ ត្រូវដាក់ (smoke alarms) នៅគ្រប់ជាន់នៃផ្ទះលោកអ្នក ។
- ☐ ត្រូវប្រើតែ (smoke alarms) ដែលស្របតាមខ្នាតអូស្ត្រាលី (Australian Standards # 3786 ) ។
- ☐ Hard wired alarms ត្រូវតែឲ្យអ្នកមានជំនាញខាងអគ្គិសនីដាក់ឲ្យ ។
- ☐ (smoke alarms) ត្រូវតែដាក់ឲ្យស្របទៅតាមសេចក្តីណែនាំរបស់ក្រុមហ៊ុនដែលផលិត (smoke alarms) នោះ ។
- ☐ ត្រូវធ្វើតេស្ត (smoke alarms) ទាំងអស់ជារឿយៗ យ៉ាងហោចណាស់ម្តងក្នុងមួយខែ ។
- ☐ លោកអ្នកគួរផ្លាស់ថ្មនៅក្នុង (smoke alarms) និមួយៗយ៉ាងហោចម្តងក្នុងមួយឆ្នាំ ។
- ☐ (smoke alarms) គួរតែផ្លាស់ដាក់ថ្មីតាមឱវាទ ព្រោះថាជីវិតរបស់វាមានកំណត់ ។
- ☐ ត្រូវតែជូតសំអាត (smoke alarms) ជារឿយៗ ដើម្បីឲ្យវាមានប្រសិទ្ធិភាព ។
- ☐ ប្រសិនបើលោកអ្នកមានកូន លោកអ្នកគួរតែគិតគូរត (smoke alarms) ដែលបញ្ចេញសម្រែកនៅពេលជាមួយគ្នា (Interconnected alarms) ។

### តើមានអ្វីទៀតដែលលោកអ្នកគួរធ្វើដើម្បីឲ្យមានសុវត្ថិភាពនៅពេលមានភ្លើងឆេះផ្ទះលោកអ្នក?

- ☐ លោកអ្នកត្រូវការផែនការមួយដែលស្តីពីអ្វីខ្លះដែលត្រូវធ្វើនៅពេល (smoke alarms) ស្រែកព្រមានលោកអ្នកពីភ្លើងឆេះ ។
- ☐ អ្នកនៅក្នុងផ្ទះរបស់លោកអ្នកទាំងអស់គួរតែរៀបចំសរសេរផែនការគេចចេញនិងហាត់តាមជារឿយៗ ។
- ☐ អ្នកដែលដេកស៊ុបដូចជាក្មេង ឬអ្នកផឹកស្រា ឬគ្រឿងញៀនប្រហែលជាមិនភ្ញាក់ពីសម្លេង (smoke alarms) ទេ ។ សូមធ្វើឲ្យប្រាកដថាអ្វីៗ
- ☐ ដែលនឹងអាចជាបញ្ហាដូចនេះត្រូវតែមាននៅក្នុងផែនការគេចចេញពីផ្ទះលោកអ្នក ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៍រលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

## ចំណុចសំខាន់ៗនៃសុវត្ថិភាព(smoke alarms)

- សូមចងចាំថាផ្សែងពីភ្លើងនឹងធ្វើឲ្យលោកអ្នកច្របូកច្របល់ហើយលោកអ្នកពុំអាចមើលឃើញនៅក្នុងផ្សែងទេ ។
- ប្រសិនបើលោកអ្នកបានគេចចេញពីភ្លើងឆេះផ្ទះ, សូមចងចាំថាកាលបើលោកអ្នកចេញហើយ សូមនៅក្រៅហើយទូរស័ព្ទលេខ ០០០ ។
- សូមបង្ហាត់កូនលោកអ្នកឲ្យចេះផែនការគេចចេញពីភ្លើងឆេះ ហើយហាត់មុននឹងមានការហ្វឹកហ្វឺននៃការគេចចេញពីភ្លើងឆេះ ។
- ប្រសិនបើសមាជិកគ្រួសារមានបញ្ហាត្រចៀកឬចលនា សូមធ្វើឲ្យប្រាកដថាលោកអ្នកគិតអំពីគេ, ហើយបើចាំបាច់, សូមចាត់ឲ្យអ្នកណាម្នាក់ជួយគេគេចចេញ ។
- សុវត្ថិភាពភ្លើងឆេះផ្ទះគឺសំខាន់ណាស់ចំពោះគ្រួសារទាំងអស់ហើយការត្រៀមលក្ខណៈជាមុនអាចការពារសោកនាដកម្មបាន ។

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ ០០០**